…អភិវឌ្ឍសេដ្ឋកិច្ចបៃតង

# សិក្ខាសាលាស្តីពី " ការរៀបចំបង្កើតផែនការអភិវឌ្ឍន៍បញ្ចេញកាបូនតិចនៅកម្ពុជា "

( ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២ )




ឯកឧត្តម **ធឹក គ្រឿងឧត្តរា** រដ្ឋលេខាធិការ ជាអធិបតីក្នុងការប្រារព្ធបើកសិក្ខាសាលា

សារធាតុកាបូន និងសារធាតុម៉េតានជាសារធាតុចម្បងពីរ គួបផ្សំជាមួយសារធាតុមួយចំនួនទៀត ដែលបានរួមផ្សំបង្កើតឲ្យមានបាតុភូតកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស ដែលជាមូលហេតុបណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុសាកលភពផែនដីពេលកន្លងមកនេះ។ សារធាតុកាបូនមានប្រភពចេញមកពីចំហេះនៃថាមពលផូសស៊ីលដែលជារ៉ែធម្មជាតិក្នុងដី មានធ្យូងថ្ម ប្រេងកាតឆៅ និងឧស្ម័ន ដែលមនុស្ស បានធ្វើអាជីវកម្មទាញយកប្រើប្រាស់ជាថាមពលជម្រុញឲ្យគ្រឿងចក្រដំណើរការ ។ដោយឡែកឧស្ម័នម៉េតាន មានប្រភពចេញមកពីកសិកម្ម មានការដាំដុះ និងការចិញ្ចឹមសត្វ ។

បច្ចុប្បន្នកំណើនកំដៅសាកលបានបង្កឲ្យភពផែនដីមានភាពមិនប្រក្រតីជាបន្តបន្ទាប់បានគម្រាមកំហែងដល់ភាវៈរស់ពិសេសការបង្កបង្កើនផលរបស់ប្រជាកសិករ ។នៅគ្រប់ទីកន្លែងលើភពផែនដី មនុស្សបានសម្គាល់ឃើញថា អាកាសធាតុប្រែប្រួលអស់ហើយតាមរយៈការបង្ហាញឲ្យឃើញពីការកើតមានរដូវកាលលែងទៀងទាត់ ។នៅកម្ពុជាមុននេះ រដូវវស្សាជារដូវដែលមានភ្លៀងធ្លាក់ពេញមួយរដូវ ហើយជារដូវដែលប្រជាកសិករធ្វើការដាំដុះដំណាំគ្រប់ប្រភេទតាមស្ថានភាពភូមិសាស្ត្រដី ។ ប៉ុន្តែឥឡូវនេះ ប្រជាកសិករខ្មែរមិនអាចអនុវត្តការដាំដុះតាមទម្លាប់ពីមុនបានទៀតទេ ព្រោះការប្រែប្រួលអាកាសធាតុវាបង្កឲ្យមានគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ខ្យល់ព្យុះសង្ឃរា ឬអាចមានបាតុភូតកូនរដូវប្រាំងក្នុងរដូវវស្សា ឬពេលខ្លះក្នុងតំបន់តែមួយ

កន្លែងខ្លះកើតមានគ្រោះទឹកជំនន់ និងកន្លែងផ្សេងទៀតកើតមានគ្រោះរាំងស្ងួត ។

ជាការឆ្លើយតបបាតុភូតប្រែប្រួលអាកាសធាតុភពផែនដីបណ្តាលមកពីផលផ្ទះកញ្ចក់ ដែលបានកើតឡើងពីកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស គោលការណ៍អភិវឌ្ឍន៍ត្រូវធានាចីរភាពបរិស្ថាន ការអភិវឌ្ឍស្អាត ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងយន្តការអភិវឌ្ឍន៍បៃតង.....ជាបរិបទថ្មីត្រូវបានលើកឡើងជាបន្តបន្ទាប់ដើម្បីទប់ស្កាត់និងកាត់បន្ថយការបញ្ចេញកាបូនហួសហេតុទៅក្នុងបរិយាកាស និងគាំពារសុខុមាល ភាពប្រជាជន ព្រមទាំងសុខភាពបរិស្ថាន។

ក្នុងស្មារតីនៃការអនុវត្តអនុសារណៈយោគយល់គ្នាស្តីពីការបង្កើតបណ្តាញស្រាវជ្រាវ ស្តីពីការអភិវឌ្ឍបញ្ចេញកាបូនតិចជាមួយវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោករបស់ប្រទេសជប៉ុន ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ ក្រសួងបរិស្ថានបានរៀបចំសិក្ខាសាលាមួយជាលើកទី២ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២ នៅសណ្ឋាគារ *ហ៊ីម៉ាវ៉ារី* ក្រោមកិច្ចសហការជាមួយវិទ្យាស្ថានជប៉ុនខាងលើ។អង្គសិក្ខាសាលានោះបានប្រព្រឹត្តឡើងក្រោមអធិបតីភាព ឯកឧត្តម **ធឹក គ្រឿនឧត្តរា** រដ្ឋលេខាធិការក្រសួងបរិស្ថាន និងលោកស្រី **តូ ម៉ូកុ** តំណាង សាកលវិទ្យាល័យតូក្យូ។ នាឱកាសនោះមានវត្តមានលោក លោក ស្រីតំណាងក្រសួង / ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ មន្ត្រីជំនាញពាក់ព័ន្ធជាច្រើនរូបចូលរួមជាសមាជិក ហើយគោលបំណងនៃសិក្ខាសាលានោះ គឺដើម្បីកសាងសមត្ថភាពនិងលើកកំពស់ការយល់ដឹងដល់អ្នកស្រាវជ្រាវ និងអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងការរៀបចំផែនការបង្កើតបណ្តាញស្រាវជ្រាវអភិវឌ្ឍន៍បញ្ចេញកាបូនតិចនៅកម្ពុជា ។



សមាជិក សមាជិកា ដែលបានចូលរួមក្នុងសិក្ខាសាលា

ក្នុងឱកាសនៃការបើកសិក្ខាសាលា បន្ទាប់ពីលោកស្រី **តូ ម៉ូកុ** បានមានចំណាប់អារម្មណ៍លើកឡើងពីការរៀបចំបង្កើតផែនការអភិវឌ្ឍន៍បញ្ចេញកាបូនតិចនៅកម្ពុជាជ្រាបរួចមក ឯកឧត្តម **ធឹក គ្រឿនឧត្តរា** រដ្ឋលេខាធិការ ដំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង បានមានប្រសាសន៍លើកឡើងថា " សិក្ខាសាលាថ្ងៃនេះជាឱកាសមួយថ្មីទៀតសម្រាប់កម្ពុជា ក្នុងការរៀបចំ និងបង្កើតបណ្តាញស្រាវជ្រាវ និងការរៀបចំផែនការអភិវឌ្ឍន៍ប្រទេសប្រកបដោយការបញ្ចេញកាបូនតិចក្នុងការ ជម្រុញឲ្យមានការអភិវឌ្ឍប្រកបដោយភាពបៃតងជាងមុន ធន់នឹងការប្រែប្រួលអាកាសធាតុ "។ ជាមួយនោះដែរ ឯកឧត្តមក៏បានលើកឡើងពីគោលនយោបាយបរិស្ថានរបស់រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានមានមតិលើកឡើងថា

*" ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ ១៩៩៥ និង បានចូលជាសមាជិកនៃពីធីសារក្យូតូនាខែកក្កដា ឆ្នាំ២០០២ ហើយកម្ពុជាក៏បានចុះហត្ថលេខាលើអនុស្សារណៈឯកភាពយល់គ្នាលើការអភិវឌ្ឍបៃតង សំដៅជម្រុញការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាពបរិស្ថានតាមរយៈការជម្រុញ និងការលើកទឹកចិត្តឲ្យមានការអភិវឌ្ឍបញ្ចេញកាបូនតិច ។ រាជរដ្ឋាភិបាលក៏បានកំណត់ទិសដៅធ្វើឲ្យកាន់តែប្រសើរឡើងនូវផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ និងផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនតាមបែបគម្រូថ្មីសម្រាប់ការអភិវឌ្ឍដោយផ្អែកលើគំនិតផ្តួចផ្តើម និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតង ហើយការអភិវឌ្ឍបញ្ចេញកាបូនតិចសំដៅបង្កើនគុណភាពអភិវឌ្ឍន៍គ្រប់វិស័យនៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពបរិស្ថាន និងការកសាងធនធានមនុស្ស ។*

មុនបញ្ចប់សុន្ទរកថានិងប្រកាសបើកសិក្ខាសាលា ឯកឧត្តម **ធឹក គ្រឿនឧត្តា** បានសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលជប៉ុន និងប្រជាជនជប៉ុនដែលបានសហការ និងឧបត្ថម្ភគាំទ្រ ប្រទេសកម្ពុជាទាំងផ្នែកបច្ចេកទេស និងថវិកាដើម្បីអភិវឌ្ឍប្រទេស ហើយឯកឧត្តមក៏បានសំណូមពរឲ្យវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោករបស់ប្រទេសជប៉ុន និងសាកលវិទ្យាល័យតូក្យូឲ្យបន្តកិច្ចសហការគាំទ្រលើផែនការគ្រប់គ្រងបរិស្ថាន និងចូលរួមដោះស្រាយការងារប្រែប្រួលអាកាសធាតុ ជាពិសេសការអភិវឌ្ឍធនធានមនុស្សនៅក្រសួងបរិស្ថាន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំនិងបង្កើតគម្រូអភិវឌ្ឍន៍ការបញ្ចេញកាបូនតិចនៅកម្ពុជា ។

សូមបញ្ជាក់ថា សិក្ខាសាលាស្តីពីការរៀបចំ បង្កើតផែនការអភិវឌ្ឍន៍ការបញ្ចេញកាបូនតិចនៅកម្ពុជា រៀបចំឡើងក្រោយកិច្ចប្រជុំកំពូលលើកទី៤ រវាងប្រទេសជប៉ុន និង បណ្តាប្រទេសតំបន់មេគង្គ (the Fourth Mekong-Japan Summit) ស្តីពីទសវត្សរ៍បៃតងជប៉ុន និងបណ្តាប្រទេសតំបន់មេគង្គ កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១២ នៅទីក្រុងតូក្យូ ។




រូបភាពអនុស្សាវរីយ៍រវាងគណៈអធិបតី និង សិក្ខាកាម

*ឯកសារ និងរូបភាព : លោក* ***ហាក់ ម៉ៅ***